ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ:.....004/20.....គ.ម.ក./ប្រ.ក.

ប្រកាស
ស្តីពី
វិសោធនកម្មលើប្រកាសលេខ ០០៤/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០០៤/១៥ គ.ម.ក./ប្រ.ក.ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៣ ខែមេសា ឆ្នាំ ២០២០

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

សម្រួច

ប្រការមួយ.- វិសោធនកម្ម

ធ្វើវិសោធនកម្មប្រការ ៤, ប្រការ ៧, ប្រការ ១១, ប្រការ ១៣, ប្រការ ១៥, ប្រការ ១៧, ប្រការ ១៩, ប្រការ ២០, ប្រការ ២៤, ប្រការ ២៦, ប្រការ ២៧, ប្រការ ៣០ និងប្រការ ៣៣ នៃប្រកាសលេខ ០០៤/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ ដែលមានខ្លឹមសារដូចខាងក្រោម÷

ប្រការ ៥ថ្មី.- ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាតក្រុមហ៊ុនសមភាគីកណ្តាល

បុគ្គលដែលមានបំណងធ្វើជាក្រុមហ៊ុនសមភាគីកណ្តាល ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាតមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

អាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើជាក្រុមហ៊ុនសមភាគីកណ្តាលមានសុពលភាពរយៈពេល ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ/ការអនុញ្ញាត។ អាជ្ញាបណ្ណ/ការអនុញ្ញាតបន្តមានសុពលភាពរយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់អស់សុពលភាព។

ករណីស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាត ក្រុមហ៊ុនសមភាគីកណ្តាលត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ឱ្យបានយ៉ាងតិច ៦០ (ហុកសិប) ថ្ងៃ មុនកាលបរិច្ឆេទផុតសុពលភាពនៃអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់។ ក្រុមហ៊ុនសមភាគីកណ្តាលនៅតែអាចប្រកបអាជីវកម្មបានរហូតដល់អគ្គនាយកនៃ **គ.ម.ក.** ពិនិត្យ និងសម្រេចផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាតបន្ត ឬផ្អាកអាជីវកម្មដោយប្រការណាមួយ។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំអំពីការយល់ព្រម ឬបដិសេធផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតដូចមានចែងក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ៣ នៃប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

ប្រការ ៧ថ្មី.- លក្ខខណ្ឌតម្រូវចំនួនចាស់មនុស្សរបស់ក្រុមហ៊ុនសមភាគីកណ្តាល

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើជាក្រុមហ៊ុនសមភាគីកណ្តាល ត្រូវមានអភិបាល ឬសហកម្មសិទ្ធិករយ៉ាងតិចមួយរូប នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ ប្រធានផ្នែកគ្រប់គ្រងហានិភ័យ ប្រធានផ្នែកព័ត៌មានវិទ្យា បុគ្គលិកជំនាញផ្នែកច្បាប់ និងប្រធានផ្នែកផ្សេងទៀត ដែលត្រូវដាក់ពាក្យស្នើសុំការទទួលស្គាល់គុណវុឌ្ឍិមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ព្រមទាំងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១-មានលក្ខណសម្បត្តិ និងអត្តចរិតល្អ។

២-ជាសមត្ថជន និងមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា។

៣-មានសញ្ញាបត្រ និងបទពិសោធន៍ដូចខាងក្រោម÷

ក-អភិបាល ឬសហកម្មសិទ្ធិករ និងនាយកប្រតិបត្តិត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងមូលបត្រ, ហិរញ្ញវត្ថុ, សេដ្ឋកិច្ច, ធុរកិច្ច, គណនេយ្យ ឬច្បាប់ ឬជាគណនេយ្យករជំនាញ (Certified Public Accountant) ឬជាអ្នកវិភាគហិរញ្ញវត្ថុជំនាញ (Chartered Financial Analyst) ឬមានសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែល ឬមានបទពិសោធន៍ការងារយ៉ាងតិច ២ (ពីរ) ឆ្នាំ ក្នុងវិស័យមូលបត្រ ឧបករណ៍និស្សន្ទ ឬហិរញ្ញវត្ថុ។

ខ-ប្រធានប្រតិបត្តិការ ប្រធានផ្នែកគ្រប់គ្រងហានិភ័យ និងប្រធានផ្នែកផ្សេងទៀត ត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងមូលបត្រ, ហិរញ្ញវត្ថុ, សេដ្ឋកិច្ច, ធុរកិច្ច ឬគណនេយ្យ ឬជាគណនេយ្យករជំនាញ ឬជាអ្នកវិភាគហិរញ្ញវត្ថុជំនាញ ឬមានសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែល ឬមានបទពិសោធន៍ការងារយ៉ាងតិច ២ (ពីរ) ឆ្នាំ ក្នុងវិស័យមូលបត្រ ឧបករណ៍និស្សន្ទ ឬហិរញ្ញវត្ថុ។

គ-ប្រធានផ្នែកព័ត៌មានវិទ្យាត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងព័ត៌មានវិទ្យា ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែល ឬមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងព័ត៌មានវិទ្យាយ៉ាងតិច ២ (ពីរ) ឆ្នាំ។

ឃ-បុគ្គលិកជំនាញផ្នែកច្បាប់ត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាផ្នែកច្បាប់ ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែល ឬមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងកិច្ចការច្បាប់យ៉ាងតិច ២ (ពីរ) ឆ្នាំ។

៤-ផ្តល់លិខិតតែងតាំងពីក្រុមហ៊ុនរបស់ខ្លួន។

៥-ចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងដែលរៀបចំដោយ **គ.ម.ភ.** ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **គ.ម.ភ.** ដែលលទ្ធផលប្រឡងមានសុពលភាព ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ភ.** ប្រកាសលទ្ធផលប្រឡង និងត្រូវចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្តដែលរៀបចំដោយ **គ.ម.ភ.** ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **គ.ម.ភ.** មុនពេលលទ្ធផលប្រឡងអស់សុពលភាព។

៦-មិនស្ថិតនៅក្រោមករណីណាមួយដូចខាងក្រោម÷

ក-មិនបានគោរពតាមសេចក្តីណែនាំផ្សេងៗដែលធ្វើឡើងដោយអនុលោមតាមប្រកាសនេះ។

ខ-ព័ត៌មាន ឬឯកសារដែលបុគ្គលដាក់ពាក្យស្នើសុំបានដាក់ជូន **គ.ម.ភ.** មានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុស។

គ-មិនទូទាត់សងបំណុលតាមសេចក្តីសម្រេចរបស់តុលាការ។

ឃ-ធ្លាប់ធ្វើជាភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ឬបុគ្គលដែលមានទំនាក់ទំនងពិសេសជាមួយគ្រឹះស្ថានហិរញ្ញវត្ថុណាមួយដែលធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយ គិតត្រឹមកាល-

បរិច្ឆេទដាក់ពាក្យស្នើសុំ លើកលែងតែបុគ្គលដែលត្រូវបានទទួលស្គាល់ដោយសេចក្តីសម្រេចរបស់តុលាការថា ពុំមានការទទួលខុសត្រូវចំពោះការក្ស័យធននេះ។

ង-ធ្លាប់ធ្វើជាភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ឬបុគ្គលដែលមានទំនាក់ទំនងពិសេសជាមួយគ្រឹះស្ថានហិរញ្ញវត្ថុណាមួយដែលអាជ្ញាបណ្ណរបស់គ្រឹះស្ថានហិរញ្ញវត្ថុនោះត្រូវបានដកហូតនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ លើកលែងតែបុគ្គលដែលត្រូវបានទទួលស្គាល់ថា ពុំមានការទទួលខុសត្រូវចំពោះការដកហូតនេះ។

ច-បានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការការពារសាធារណជន។

ឆ-ធ្លាប់ប្រព្រឹត្តអំពើមិនស្មោះត្រង់ ឬធ្លាប់ប្រព្រឹត្តមិនត្រឹមត្រូវ ឬជាបុគ្គលអសមត្ថភាពក្នុងការផ្តល់សេវាហិរញ្ញវត្ថុ ឬការគ្រប់គ្រងក្រុមហ៊ុន។

ជ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀតដែលធ្វើឲ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន។

ឈ-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ញ-ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាពដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួនដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ។

ដ-ធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

ឋ-ធ្លាប់បានទទួលអាជ្ញាបណ្ណពី **គ.ម.ភ.** ដែលអាជ្ញាបណ្ណនោះត្រូវបានដកហូត ឬព្យួរទុក ឬធ្លាប់ប្រព្រឹត្តអំពើល្មើសដែលមានចែងក្នុងច្បាប់។

ឌ-ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ និងយុត្តិធម៌។

ឍ-មាន ឬអាចនឹងមានការពាក់ព័ន្ធនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬការផ្តល់ការទទួលស្គាល់គុណវុឌ្ឍិដល់បុគ្គលដាក់ពាក្យស្នើសុំ អាចនឹងនាំឲ្យប៉ះពាល់ផលប្រយោជន៍សាធារណៈ ឬនាំឲ្យមានទំនាស់ផលប្រយោជន៍។

បុគ្គលដាក់ពាក្យស្នើសុំការទទួលស្គាល់គុណវុឌ្ឍិដូចមានចែងក្នុងប្រការនេះ ត្រូវបង់ថ្លៃពាក្យស្នើសុំចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់ និងសៅហ៊ុយសិក្សាសំណុំលិខិតចំនួន ១០០.០០០ (មួយរយពាន់) រៀល នៅ **គ.ម.ភ.** នៅពេលដាក់ពាក្យស្នើសុំ។ ថ្លៃពាក្យស្នើសុំ និងសៅហ៊ុយសិក្សាសំណុំលិខិតអនុលោមតាមប្រការនេះ មិនត្រូវបានប្រគល់ជូនបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីការស្នើសុំត្រូវបានបដិសេធក៏ដោយ។

ក្រុមហ៊ុនសមភាគីកណ្តាលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **គ.ម.ភ.** អំពីអវត្តមានពីក្រុមហ៊ុន

ដោយគ្មានមូលហេតុ ការលាឈប់ ការបញ្ចប់តួនាទី ឬការផ្លាស់ប្តូរមុខងាររបស់បុគ្គលដែលទទួលបានការទទួលស្គាល់គុណវុឌ្ឍិពី **គ.ម.ក.** ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីអវត្តមានពីក្រុមហ៊ុនដោយគ្មានមូលហេតុរយៈពេល ៧ (ប្រាំពីរ) ថ្ងៃជាប់ៗគ្នា ឬទទួលបានការជូនដំណឹងឬលិខិតលាឈប់ពីការងារ ការសម្រេចបញ្ចប់តួនាទី ឬការផ្លាស់ប្តូរមុខងាររបស់បុគ្គលនោះ។

អគ្គនាយកនៃ **គ.ម.ក.** អាចលុបចោលការទទួលស្គាល់គុណវុឌ្ឍិ ក្នុងករណីបុគ្គលដែលទទួលបានការទទួលស្គាល់គុណវុឌ្ឍិអនុលោមតាមកថាខណ្ឌទី ១ នៃប្រការនេះ ស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម÷

១-ក្លាយជាអសមត្ថជន។

២-លាឈប់ ឬផ្លាស់ប្តូរមុខងារ។

៣-ហេតុការណ៍ណាមួយដែលបុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិមិនអាចអនុវត្តការងារបាន។

៤-ល្មើសនឹងកថាខណ្ឌទី ១ នៃប្រការនេះ។

ប្រការ ១១ថ្មី.- ការផ្លាស់ប្តូរបុគ្គលទទួលស្គាល់គុណវុឌ្ឍិរបស់ក្រុមហ៊ុនសមភាគីកណ្តាល

ក្រុមហ៊ុនសមភាគីកណ្តាលត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** មុននឹងតែងតាំង ឬផ្លាស់ប្តូរអភិបាល ឬសហកម្មសិទ្ធិករទទួលបានការទទួលស្គាល់គុណវុឌ្ឍិ នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ ប្រធានផ្នែកគ្រប់គ្រងហានិភ័យ ប្រធានផ្នែកព័ត៌មានវិទ្យា បុគ្គលិកជំនាញផ្នែកច្បាប់ និងប្រធានផ្នែកផ្សេងទៀត។

ប្រសិនតំណែងសម្រាប់អភិបាល ឬសហកម្មសិទ្ធិករទទួលបានការទទួលស្គាល់គុណវុឌ្ឍិ នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ ប្រធានផ្នែកគ្រប់គ្រងហានិភ័យ ប្រធានផ្នែកព័ត៌មានវិទ្យា បុគ្គលិកជំនាញផ្នែកច្បាប់ និងប្រធានផ្នែកផ្សេងទៀតនៅទំនេរ ក្រុមហ៊ុនសមភាគីកណ្តាលត្រូវជ្រើសរើសបេក្ខភាពថ្មី និងដាក់ពាក្យស្នើសុំការទទួលស្គាល់គុណវុឌ្ឍិមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ក្នុងរយៈពេលយ៉ាងយូរ ១ (មួយ) ខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ ឬក្នុងរយៈពេលសមស្របណាមួយដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.**។

ប្រការ ១៣ថ្មី.- ថ្លៃពាក្យស្នើសុំ សោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃអាជ្ញាបណ្ណ/ការអនុញ្ញាតក្រុមហ៊ុនសមភាគីកណ្តាល

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាក្រុមហ៊ុនសមភាគីកណ្តាល ត្រូវបង់ថ្លៃពាក្យស្នើសុំចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់ និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ៤.០០០.០០០ (បួនលាន) រៀល នៅ **គ.ម.ក.** នៅពេលដាក់ពាក្យស្នើសុំ ព្រមទាំងត្រូវបង់ថ្លៃអាជ្ញាបណ្ណចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំ និងថ្លៃអាជ្ញាបណ្ណបន្តចំនួន ១២០.០០០.០០០ (មួយរយម្ភៃលាន) រៀល សម្រាប់រយៈពេល ៣ (បី) ឆ្នាំ។

ក្រុមហ៊ុនមូលបត្រដែលដាក់ពាក្យស្នើសុំការអនុញ្ញាត ឬបន្តការអនុញ្ញាតធ្វើជាក្រុមហ៊ុនសមភាគីកណ្តាល ត្រូវបង់ថ្លៃពាក្យស្នើសុំចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់ និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ២.០០០.០០០ (ពីរលាន) រៀល នៅ **គ.ម.ក.** នៅពេលដាក់ពាក្យស្នើសុំ ព្រមទាំងត្រូវបង់ថ្លៃការអនុញ្ញាតចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំ និងថ្លៃការអនុញ្ញាតបន្តចំនួន

៦០.០០០.០០០ (ហុកសិបលាន) រៀល សម្រាប់រយៈពេល ៣ (បី) ឆ្នាំ។

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតអនុលោមតាមប្រការនេះ មិនត្រូវបានប្រគល់ជូនទៅបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីការស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ/ការអនុញ្ញាត ត្រូវបានបដិសេធក៏ដោយ។

ក្រុមហ៊ុនសមភាគីកណ្តាលដែលដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតទៅ **គ.ម.ក.** តិចជាង ៦០ (ហុកសិប) ថ្ងៃ មុនកាលបរិច្ឆេទដែលអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់អស់សុពលភាព ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាសាច់ប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ក្នុងមួយថ្ងៃ ចំពោះការដាក់ពាក្យស្នើសុំយឺតយ៉ាវនេះ។

ប្រការ ១៥ថ្មី.- អាជ្ញាបណ្ណ/ការអនុញ្ញាតឈ្មួញជើងសាទ្វបករណ៍និស្សន្ទ និងភ្នាក់ងារជើងសាទ្វបករណ៍និស្សន្ទ

គ្មានបុគ្គលណាមួយអាចធ្វើជាឈ្មួញជើងសាឧបករណ៍និស្សន្ទ ឬតាំងខ្លួនជាឈ្មួញជើងសាឧបករណ៍និស្សន្ទបានទេ លើកលែងតែបុគ្គលនោះទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

គ្មានបុគ្គលណាមួយអាចធ្វើជាភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ឬតាំងខ្លួនជាភ្នាក់ងារជើងសាឧបករណ៍និស្សន្ទបានទេ លើកលែងតែបុគ្គលនោះទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.ម.ក.**។

កិច្ចសន្យាឧបករណ៍និស្សន្ទសម្រាប់គោលបំណងការពារហានិភ័យរបស់អតិថិជនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមិនមានលក្ខណៈស្តង់ដា (Non-Standardized) មិនអាចធ្វើសំណើលក់ជាសាធារណៈ និងមិនអាចផ្ទេរបាន (Non-Transferable) ឬមិនអាចជួញដូរបាន (Non-Tradable) ហើយត្រូវបានរក្សាទុកដល់ឥណប្រតិទាន មិនស្ថិតនៅក្រោមវិសាលភាពនៃប្រកាសនេះទេ។

ក្រុមហ៊ុនមូលបត្រ/ក្រុមហ៊ុនសមភាគីកណ្តាលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.** អាចដាក់ពាក្យស្នើសុំការអនុញ្ញាតបន្ថែម ដើម្បីធ្វើជាឈ្មួញជើងសាឧបករណ៍និស្សន្ទអនុលោមតាមប្រកាសនេះ មកអគ្គនាយកនៃ **គ.ម.ក.**។ ក្រុមហ៊ុនដែលទទួលបានការអនុញ្ញាតជាឈ្មួញជើងសាឧបករណ៍និស្សន្ទ ត្រូវធ្វើអាជីវកម្មជាឈ្មួញជើងសាឧបករណ៍និស្សន្ទដាច់ដោយឡែកពីអាជីវកម្មដែលខ្លួនមាន ដោយត្រូវមានទីតាំងអាជីវកម្ម បរិក្ខារ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ធនធានមនុស្សដាច់ដោយឡែកពីគ្នា និងត្រូវមានរបាំងព័ត៌មានសមស្រប។

ប្រការ ១៧ថ្មី.- ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាតឈ្មួញជើងសាទ្វបករណ៍និស្សន្ទ និងភ្នាក់ងារជើងសាទ្វបករណ៍និស្សន្ទ

បុគ្គលដែលមានបំណងធ្វើជាឈ្មួញជើងសាឧបករណ៍និស្សន្ទ ឬភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាតមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

អាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើជាឈ្មួញជើងសាឧបករណ៍និស្សន្ទ និងអាជ្ញាបណ្ណភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ មានសុពលភាពរយៈពេល ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ/ការអនុញ្ញាត។ អាជ្ញាបណ្ណ/ការអនុញ្ញាតបន្តមានសុពលភាពរយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទអាជ្ញាបណ្ណ/ការអនុញ្ញាត

ចាស់អស់សុពលភាព។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតមក **គ.ម.ភ.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ភ.** ឱ្យបានយ៉ាងតិច ៦០ (ហុកសិប) ថ្ងៃ មុនកាលបរិច្ឆេទអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់អស់សុពលភាព និងភ្នាក់ងារជើងសាឧបករណ៍និស្សន្ទត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណមក **គ.ម.ភ.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ភ.** ឱ្យបានយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទអាជ្ញាបណ្ណចាស់អស់សុពលភាព។ ឈ្មួញជើងសាឧបករណ៍និស្សន្ទ និងភ្នាក់ងារជើងសាឧបករណ៍និស្សន្ទនៅតែអាចធ្វើសកម្មភាពអាជីវកម្មបានរហូតដល់អគ្គនាយកនៃ **គ.ម.ភ.** ពិនិត្យ និងសម្រេចផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាតបន្ត ឬផ្អាកសកម្មភាពអាជីវកម្មដោយប្រការណាមួយ។

អគ្គនាយកនៃ **គ.ម.ភ.** ត្រូវចាត់ចែងការចុះត្រួតពិនិត្យដល់ទីកន្លែង ដើម្បីផ្ទៀងផ្ទាត់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត ឬដើម្បីធ្វើការត្រួតពិនិត្យនូវរាល់ព័ត៌មាន ទិន្នន័យ ឯកសារ និងប្រតិបត្តិការពាក់ព័ន្ធនឹងអាជីវកម្មរបស់ឈ្មួញជើងសាឧបករណ៍និស្សន្ទ។

អគ្គនាយកនៃ **គ.ម.ភ.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំ អំពីការយល់ព្រម ឬបដិសេធផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតឈ្មួញជើងសាឧបករណ៍និស្សន្ទ ក្នុងរយៈពេលយ៉ាងយូរ ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ភ.** ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

អគ្គនាយកនៃ **គ.ម.ភ.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំ អំពីការយល់ព្រម ឬបដិសេធផ្តល់អាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ភ.** ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

ប្រការ ១៩ថ្មី.- លក្ខខណ្ឌតម្រូវមូលធនរបស់ឈ្មួញជើងសាឧបករណ៍និស្សន្ទ

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាឈ្មួញជើងសាឧបករណ៍និស្សន្ទ ត្រូវមានដើមទុនអប្បបរមាចំនួន ២.000.000.000 (ពីរប៊ីលាន) រៀល និងត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១៥ (ដប់ប្រាំ) ភាគរយនៃដើមទុនក្នុងគណនីរបស់ **គ.ម.ភ.** នៅធនាគារជាតិនៃកម្ពុជា។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវរក្សាមូលធនរួមបញ្ចូលទាំងប្រាក់ចំណេញរក្សាទុក និងប្រាក់បម្រុងរក្សាទុកឱ្យមានសមាមាត្រជាមួយនឹងហានិភ័យពាក់ព័ន្ធនឹងអាជីវកម្មរបស់ខ្លួន និងត្រូវរក្សាមូលធនភាគហ៊ុនិកឱ្យបានយ៉ាងតិចស្មើនឹងដើមទុនអប្បបរមាដូចមានកំណត់ក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

ក្រុមហ៊ុនមូលបត្រដែលដាក់ពាក្យស្នើសុំការអនុញ្ញាតធ្វើជាឈ្មួញជើងសាឧបករណ៍និស្សន្ទ ត្រូវបានលើកលែងលក្ខខណ្ឌតម្រូវដើមទុនអប្បបរមាដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ ប៉ុន្តែត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មបន្ថែមដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

ក្រុមហ៊ុនសមភាគីកណ្តាលដែលដាក់ពាក្យស្នើសុំការអនុញ្ញាតធ្វើជាឈ្មួញជើងសាឧបករណ៍និស្សន្ទបន្ថែម មិនតម្រូវឱ្យអនុវត្តលក្ខខណ្ឌតម្រូវដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

ប្រការ ២០ថ្មី.- លក្ខខណ្ឌតម្រូវចាំបាច់សម្រាប់ឈ្មួញជើងសាខុបករណ៍និស្សន្ទ

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើជាឈ្មួញជើងសាខុបករណ៍និស្សន្ទត្រូវមាន÷

១-អភិបាល ឬសហកម្មសិទ្ធិករយ៉ាងតិចមួយរូប នាយកប្រតិបត្តិ និងបុគ្គលិកជំនាញផ្នែកច្បាប់ដែលត្រូវដាក់ពាក្យស្នើសុំការទទួលស្គាល់គុណវុឌ្ឍិមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ព្រមទាំងត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៧ថ្មី នៃប្រកាសនេះ។

២-មានភ្នាក់ងារជើងសាខុបករណ៍និស្សន្ទដែលត្រូវទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.ម.ក.**។ បុគ្គលដាក់ពាក្យស្នើសុំត្រូវមានចំនួនភ្នាក់ងារជើងសាខុបករណ៍និស្សន្ទសមាមាត្រទៅតាមទំហំអាជីវកម្មរបស់ខ្លួន។

៣-បុគ្គលិកជំនាញផ្សេងទៀត។

បុគ្គលដាក់ពាក្យស្នើសុំការទទួលស្គាល់គុណវុឌ្ឍិត្រូវបង់ថ្លៃពាក្យស្នើសុំចំនួន ២០.០០០ (ម្ភៃពាន់) រៀលក្នុងមួយច្បាប់ និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ១០០.០០០ (មួយរយពាន់) រៀល នៅ **គ.ម.ក.** នៅពេលដាក់ពាក្យស្នើសុំ។ ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតអនុលោមតាមប្រការនេះ មិនត្រូវបានប្រគល់ជូនបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីការស្នើសុំត្រូវបានបដិសេធក៏ដោយ។

ឈ្មួញជើងសាខុបករណ៍និស្សន្ទត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **គ.ម.ក.** អំពីអវត្តមានពីក្រុមហ៊ុនដោយគ្មានមូលហេតុ ការលាឈប់ ការបញ្ចប់តួនាទី ឬការផ្លាស់ប្តូរមុខងាររបស់បុគ្គលដែលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ និងភ្នាក់ងារជើងសាខុបករណ៍និស្សន្ទរបស់ខ្លួនក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីអវត្តមានពីក្រុមហ៊ុនដោយគ្មានមូលហេតុរយៈពេល ៧ (ប្រាំពីរ) ថ្ងៃជាប់ៗគ្នា ឬទទួលបានការជូនដំណឹងឬលិខិតលាឈប់ពីការងារ ការសម្រេចបញ្ចប់តួនាទី ឬការផ្លាស់ប្តូរមុខងាររបស់បុគ្គល និងភ្នាក់ងារនោះ។

អគ្គនាយកនៃ **គ.ម.ក.** អាចលុបចោលការទទួលស្គាល់គុណវុឌ្ឍិ ក្នុងករណីបុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម÷

១-ក្លាយជាអសមត្ថជន។

២-លាឈប់ ឬផ្លាស់ប្តូរមុខងារ។

៣-ហេតុការណ៍ណាមួយដែលបុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិមិនអាចអនុវត្តការងារបាន។

៤-ល្មើសនឹងចំណុចទី ១ នៃកថាខណ្ឌទី ១ នៃប្រការនេះ។

ប្រការ ២៤ថ្មី.- ការផ្លាស់ប្តូរបុគ្គលទទួលស្គាល់គុណវុឌ្ឍិរបស់ឈ្មួញជើងសាខុបករណ៍និស្សន្ទ

ឈ្មួញជើងសាខុបករណ៍និស្សន្ទត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** មុននឹងតែងតាំង ឬផ្លាស់ប្តូរអភិបាល ឬសហកម្មសិទ្ធិករទទួលបានការទទួលស្គាល់គុណវុឌ្ឍិ នាយកប្រតិបត្តិ និងបុគ្គលិកជំនាញផ្នែកច្បាប់។

ប្រសិនតំណែងសម្រាប់អភិបាល ឬសហកម្មសិទ្ធិករទទួលបានការទទួលស្គាល់គុណវុឌ្ឍិ នាយកប្រតិបត្តិ

បុគ្គលិកជំនាញផ្នែកច្បាប់ និងភ្នាក់ងារជើងសាឧបករណ៍និស្សន្ទនៅទំនេរ ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវជ្រើសរើសបេក្ខភាពថ្មី និងដាក់ពាក្យស្នើសុំការទទួលស្គាល់គុណវុឌ្ឍិ និងអាជ្ញាបណ្ណមក **គ.ម.ភ.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ភ.** ក្នុងរយៈពេលយ៉ាងយូរ ១ (មួយ) ខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ ឬក្នុងរយៈពេលសមស្របណាមួយដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ភ.**។

ប្រការ ២៦ថ្មី.- ការបើកគណនីជួញដូរឧបករណ៍និស្សន្ទ

វិនិយោគិនត្រូវបើកគណនីជួញដូរឧបករណ៍និស្សន្ទនៅឈ្មួញជើងសាឧបករណ៍និស្សន្ទ។ ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវធានាថាសាច់ប្រាក់របស់អតិថិជននីមួយៗនៅក្នុងគណនីជួញដូរ និងគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រមិនលើសពី ២០០.០០០.០០០ (ពីររយលាន) រៀល ឬ ៥០.០០០ (ហាសិបពាន់) ដុល្លារអាមេរិក លើកលែងតែអតិថិជននោះជាវិនិយោគិនគុណវុឌ្ឍិដែលបំពេញលក្ខខណ្ឌតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

គ.ម.ភ. អាចធ្វើការកែប្រែនូវទំហំសាច់ប្រាក់ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃប្រការនេះក្នុងរយៈពេល ២ (ពីរ) ឆ្នាំម្តង ឬតាមការចាំបាច់។

ក្រុមហ៊ុនសមភាគីកណ្តាលត្រូវរៀបចំប្រព័ន្ធជួញដូរដែលតម្រូវឱ្យបិទស្ថានភាពជួញដូរ (Close Positions) របស់អតិថិជនជាស្វ័យប្រវត្តិក្នុងករណីអតិថិជននោះរងកំហាតដល់ ៥០ (ហាសិប) ភាគរយនៃសាច់ប្រាក់របស់ខ្លួន។

ប្រការ ២៧ថ្មី.- ថ្លៃពាក្យស្នើសុំ សោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃអាជ្ញាបណ្ណ/ការអនុញ្ញាតឈ្មួញជើងសាឧបករណ៍និស្សន្ទ

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាឈ្មួញជើងសាឧបករណ៍និស្សន្ទ ត្រូវបង់ថ្លៃពាក្យស្នើសុំចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់ និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ២.០០០.០០០ (ពីរលាន) រៀល នៅ **គ.ម.ភ.** នៅពេលដាក់ពាក្យស្នើសុំ ព្រមទាំងត្រូវបង់ថ្លៃអាជ្ញាបណ្ណចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំ និងថ្លៃអាជ្ញាបណ្ណបន្តចំនួន ៣០.០០០.០០០ (សាមសិបលាន) រៀល សម្រាប់រយៈពេល ៣ (បី) ឆ្នាំ។

ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនសមភាគីកណ្តាលដែលដាក់ពាក្យស្នើសុំការអនុញ្ញាត ឬបន្តការអនុញ្ញាតធ្វើជាឈ្មួញជើងសាឧបករណ៍និស្សន្ទ ត្រូវបង់ថ្លៃពាក្យស្នើសុំចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់ និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ១.០០០.០០០ (មួយលាន) រៀល នៅ **គ.ម.ភ.** នៅពេលដាក់ពាក្យស្នើសុំ និងត្រូវបង់ថ្លៃការអនុញ្ញាតចំនួន ១០.០០០.០០០ (ដប់លាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំ និងថ្លៃការអនុញ្ញាតបន្តចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល សម្រាប់រយៈពេល ៣ (បី) ឆ្នាំ។

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ ត្រូវបង់ថ្លៃពាក្យស្នើសុំចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់ និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ១០០.០០០ (មួយរយពាន់) រៀល នៅ **គ.ម.ភ.** នៅពេលដាក់ពាក្យស្នើសុំ និងត្រូវបង់ថ្លៃអាជ្ញាបណ្ណចំនួន ៤០០.០០០ (បួន

រយពាន់) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំ និងថ្លៃអាជ្ញាបណ្ណបន្តចំនួន ៦០០.០០០ (ប្រាំមួយរយពាន់) រៀលសម្រាប់រយៈពេល ៣ (បី) ឆ្នាំ។

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតអនុលោមតាមប្រការនេះ មិនត្រូវបានប្រគល់ជូនបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីការស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវបានបដិសេធក៏ដោយ។

ឈ្មួញជើងសាឧបករណ៍និស្សន្ទដែលដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតនៅ **គ.ម.ក.** តិចជាង ៦០ (ហុកសិប) ថ្ងៃ មុនកាលបរិច្ឆេទដែលអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់អស់សុពលភាព ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាសាច់ប្រាក់ចំនួន ៥០០.០០០ (ប្រាំរយពាន់) រៀល ក្នុងមួយថ្ងៃ ចំពោះការដាក់ពាក្យស្នើសុំយឺតយ៉ាវនេះ។

ភ្នាក់ងារជើងសាឧបករណ៍និស្សន្ទដែលដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណនៅ **គ.ម.ក.** តិចជាង ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទដែលអាជ្ញាបណ្ណចាស់អស់សុពលភាព ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាសាច់ប្រាក់ចំនួន ១០០.០០០ (មួយរយពាន់) រៀល ក្នុងមួយថ្ងៃ ចំពោះការដាក់ពាក្យស្នើសុំយឺតយ៉ាវនេះ។

ប្រការ ៣០ថ្មី.- ថ្លៃសេវាលើប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទ

ឈ្មួញជើងសាឧបករណ៍និស្សន្ទនៃភាគីអ្នកលក់ និងឈ្មួញជើងសាឧបករណ៍និស្សន្ទនៃភាគីអ្នកទិញ ត្រូវបង់ថ្លៃសេវាលើប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទជូន **គ.ម.ក.** តាមរយៈក្រុមហ៊ុនសមភាគីកណ្តាលក្នុងអត្រាដែលកំណត់ដោយប្រធាន **គ.ម.ក.** តាមសំណើរបស់អគ្គនាយកនៃ **គ.ម.ក.**។

ក្រុមហ៊ុនសមភាគីកណ្តាលត្រូវប្រមូលថ្លៃសេវាលើប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទដូចមានចែងនៅក្នុងកថាខណ្ឌទី ១ នៃប្រការនេះជូន **គ.ម.ក.**។

ក្រុមហ៊ុនសមភាគីកណ្តាលត្រូវផ្តល់ជូន **គ.ម.ក.** នូវរបាយការណ៍ពាក់ព័ន្ធនឹងថ្លៃសេវាលើប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទដែលប្រមូលបានដូចមានចែងក្នុងប្រការនេះ និងបង់ប្រាក់ថ្លៃសេវាទាំងនេះជាប្រចាំខែជូន **គ.ម.ក.** ក្នុងរយៈពេលមិនលើសពីថ្ងៃទី១០ នៃខែបន្ទាប់ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.**។

អគ្គនាយកនៃ **គ.ម.ក.** អាចចាត់ឱ្យមានការត្រួតពិនិត្យ និងសវនកម្មពាក់ព័ន្ធនឹងថ្លៃសេវាលើប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទដូចមានកំណត់នៅក្នុងប្រការនេះ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទ។

ក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវបង់ ០,៥ (ស្មសិបក្បៀសប្រាំ) ភាគរយនៃប្រាក់ចំណេញមុនបង់ពន្ធប្រចាំឆ្នាំរបស់ក្រុមហ៊ុនជូន **គ.ម.ក.** ជាប្រចាំឆ្នាំ សម្រាប់ជាមូលនិធិសម្រាប់អភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជា ក្នុងរយៈពេលយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់ ឬក្នុងរយៈពេលសមស្របណាមួយដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.**។

ប្រការ ៣៣ថ្មី.- ការផ្លាស់ប្តូរ ឬការកែប្រែ

ក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ

គ.ម.ភ. មុននឹង÷

១-ផ្លាស់ប្តូរ ឬកែប្រែតំណាងនៃភាគហ៊ុនិកជានីតិបុគ្គល សមាសភាពក្រុមប្រឹក្សាភិបាល រចនាសម្ព័ន្ធភាគហ៊ុនិក ដើមទុន នាមករណ៍ ទម្រង់ក្រុមហ៊ុន ឬទីស្នាក់ការ។

២-ប្រើប្រាស់ ឬកែប្រែថ្លៃសេវា ឬកម្រៃជើងសាផ្សេងៗ។

ក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្តត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតនៅ **គ.ម.ភ.** នៅពេលដាក់ពាក្យស្នើសុំនៅ **គ.ម.ភ.** ទៅតាមប្រភេទនៃការផ្លាស់ប្តូរ ឬកែប្រែដូចខាងក្រោម÷

១-២០០.០០០ (ពីររយពាន់) រៀល សម្រាប់ការផ្លាស់ប្តូរ ឬកែប្រែទីស្នាក់ការចុះបញ្ជី។

២-១០០.០០០ (មួយរយពាន់) រៀល សម្រាប់ការផ្លាស់ប្តូរ ឬកែប្រែតំណាងនៃភាគហ៊ុនិកជានីតិបុគ្គល និងសមាសភាពក្រុមប្រឹក្សាភិបាល។

៣-៦០.០០០ (ហុកសិបពាន់) រៀល សម្រាប់ការផ្លាស់ប្តូរ ឬកែប្រែនាមករណ៍ និងទម្រង់ក្រុមហ៊ុន។

ក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្តត្រូវបង់សោហ៊ុយនៃការផ្ទេរភាគហ៊ុននៅពេលដាក់ពាក្យស្នើសុំការអនុញ្ញាតផ្ទេរភាគហ៊ុននៅ **គ.ម.ភ.** ចំនួន ០,៥ (សូន្យក្បៀសប្រាំ) ភាគរយនៃភាគហ៊ុនដែលបានផ្ទេរ ឬស្មើនឹង ៤០.០០០.០០០ (សែសិបលាន) រៀល ក្នុងករណីដែលធំជាងនេះ។ សោហ៊ុយនៃការផ្ទេរភាគហ៊ុននេះមិនអនុវត្តចំពោះការផ្ទេរភាគហ៊ុនដែលក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្តបានបោះផ្សាយលក់ជាសាធារណៈ។

ក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្តត្រូវបង់សោហ៊ុយនៅពេលដាក់ពាក្យស្នើសុំការអនុញ្ញាតបង្កើន ឬបន្ថយដើមទុននៅ **គ.ម.ភ.** ចំនួន ០,០៣ (សូន្យក្បៀសសូន្យបី) ភាគរយនៃចំនួនសាច់ប្រាក់ដែលសុំបង្កើន ឬបន្ថយ។

សោហ៊ុយសិក្សាសំណុំលិខិតអនុលោមតាមប្រការនេះ មិនត្រូវបានប្រគល់ជូនបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីការស្នើសុំត្រូវបានបដិសេធក៏ដោយ។

ប្រការពីរ.- លក្ខខណ្ឌតម្រូវបន្ថែមសម្រាប់ការផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាតបន្ត

ឈ្មួញជើងសាឧបករណ៍និស្សន្តដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **គ.ម.ភ.** មុនដាក់ឱ្យអនុវត្តន្វប្រកាសនេះ ត្រូវអនុវត្តលក្ខខណ្ឌតម្រូវដើមទុនអប្បបរមាថ្មី មូលធនភាគហ៊ុនិកថ្មី និងប្រាក់តម្កល់ធានាអាជីវកម្មថ្មីអនុលោមតាមប្រកាសនេះ នៅពេលដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាត។

ក្រុមហ៊ុនសមភាគីកណ្តាលត្រូវបំពេញលក្ខខណ្ឌតម្រូវបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតបន្ថែមដូចជា បានទិញឬលក់ឧបករណ៍និស្សន្តជាមួយវិនិយោគិន បានផ្សព្វផ្សាយអំពីវិស័យឧបករណ៍និស្សន្តដល់សាធារណជនតាមរយៈការរៀបចំសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាល ក្នុងចំនួន ឬទំហំ និង/ឬបំពេញលក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ភ.** ក្នុងអំឡុងសុពលភាពអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់។

ឈ្មួញជើងសាឧបករណ៍និស្សន្តត្រូវបំពេញលក្ខខណ្ឌតម្រូវបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតបន្ថែមដូចជា បានទិញ ឬលក់ឧបករណ៍និស្សន្តតាមបញ្ជារបស់អតិថិជនរបស់ខ្លួន បានផ្សព្វផ្សាយអំពីវិស័យឧបករណ៍និស្សន្តដល់

សាធារណជនតាមរយៈការរៀបចំសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាល ក្នុងចំនួន ឬទំហំ និង/ឬបំពេញលក្ខខណ្ឌ ផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ក្នុងអំឡុងសុពលភាពអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់។

ប្រការបី.- អានុភាពអនុវត្ត

ប្រកាសនេះត្រូវមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ប្រការបួន.- បដិវាទកម្ម

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការប្រាំ.- ការអនុវត្ត

អគ្គនាយកនៃ **គ.ម.ក.** ប្រធាននាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិ-យុត្ត គ្រប់ប្រធាននាយកដ្ឋាន-អង្គភាពស្ថិតនៅចំណុះឱ្យ **គ.ម.ក.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំជូត ទោស័ក ព.ស.[illegible]
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០២០

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការប្រាំ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ